ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ធំ**

សំណុំរឿងរដ្ឋប្បវេណី

លេខ ៩១

ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២

សាលក្រមលេខ ១៥(ក)

ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២

កាលបរិច្ឆេទ ប្រកាសសាលក្រម

ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២

តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងខេត្តកំពង់ធំ

បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ធំ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២

បានប្រកាសសាលក្រមនៅចំពោះមុខគូភាគីនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ប្រធាន និងជាចៅក្រមសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ

ដែលមានគូភាគី៖

-ដើមចោទ ឈ្មោះ [redacted] មនោរិទ្ធ ភេទប្រុស អាយុ ៤៣ឆ្នាំ ជាតិខ្មែរ សព្វថ្ងៃនៅភូមិពោធិសែនស្ពាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

-ចុងចម្លើយ ឈ្មោះ [redacted] សេរីកញ្ញា ភេទស្រី អាយុ ៣១ឆ្នាំ ជាតិខ្មែរ សព្វថ្ងៃនៅភូមិពោធិសែនស្ពាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

**១. ការទាមទាររបស់ដើមចោទ៖**

ដើមចោទបានប្តឹងសុំឲ្យតុលាការចេញសាលក្រមសម្រេច៖

១-សុំលែងលះពីប្រពន្ធឈ្មោះ [redacted] សេរីកញ្ញា ឲ្យបានដាច់ស្រឡះចាប់ពីថ្ងៃនេះតទៅ។

២-សុំគ្រប់គ្រងកូនពីរនាក់១.ឈ្មោះ [redacted] ហេងហេង ភេទស្រី អាយុ ១៤ឆ្នាំ ២.ឈ្មោះ [redacted] វិជ្ជោត ភេទប្រុស អាយុ ១២ឆ្នាំ។

៣.សុំបែងចែកទ្រព្យរួមមាន៖

ក.ផ្ទះថ្មក្រោម ឈើខាងលើ ទំហំ ៧ម៉ែត្រ គុណ ២៤ម៉ែត្រ ដែលសង់នៅលើដីលំនៅដ្ឋានទំហំ ១០ម៉ែត្រ គុណ ៣០ម៉ែត្រ ស្ថិតនៅភូមិពោធិសែនស្ពាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

ខ.រថយន្តម៉ាកក្លូវឡា ពណ៌ក្រហម ផលិតនៅឆ្នាំ២០០១ ផ្លាកលេខ ភ្នំពេញ ២R ០០៨៧ តម្លៃ ១០៥០០ដុល្លាអាមេរិច ដែលប្រពន្ធជាអ្នកគ្រប់គ្រងសព្វថ្ងៃ។



Scanned with CamScanner

គ.ផ្ទះសំណាក់យីហោឈានឡើង ទំហំ ១១ម៉ែត្រ គុណ ២៤ម៉ែត្រ និងបន្ទប់ខារ៉ាអូខេ ដែលសង់លើដីលំនៅដ្ឋានទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ។

ឃ.ដីលំនៅដ្ឋានទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ។

៤.បំណុលរួមមាន៖

ក.ជំពាក់បងប្អូនចំនួន ៤៨ ៨៤២ដុល្លារអាមេរិច

ខ.បងឡាសំណង់ចំនួន ៤០០០ដុល្លារអាមេរិច

គ.បងសានចំនួន ៩៥០០ដុល្លារអាមេរិច

ឃ.បងរ៉ុចំនួន ១៨០០ដុល្លារអាមេរិច

ង.ធនាគារអេស៊ីលីដាចំនួន ១២០០០ដុល្លារអាមេរិច

ច.ជំពាក់ថ្លៃភ្លើងចំនួន ៥០០ដុល្លារអាមេរិច

ង.បងហៃចំនួន ៣០០ដុល្លារអាមេរិច

ច.ពូឡេឡាចំនួន ៣០០ដុល្លារអាមេរិច

ឆ.ឈ្មោះ ផល ចំនួន ៣០០ដុល្លារអាមេរិច

សរុបបំណុលរួម ៧៧៥០០ដុល្លារអាមេរិច។

## ២. ការអះអាងរបស់គូភាគី

-ដើមចោទឈ្មោះ [redacted] មនោរិទ្ធ បានធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយតាំងពីឆ្នាំ១៩៩៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅឆ្នាំ២០០៧។ ការរួមរស់ជាមួយគ្នានេះពួកខ្លួនមានកូនពីរនាក់ម្នាក់ឈ្មោះ [redacted] ហេងហេង ភេទស្រី អាយុ ១៤ឆ្នាំ និងម្នាក់ទៀតឈ្មោះ [redacted] វិជ្ជាត ភេទប្រុស អាយុ ១២ឆ្នាំ។ ចំពោះកូនទាំងពីរនេះ ខ្លួនសុំគ្រប់គ្រប់ទាំងពីរ ព្រោះកូនទាំងពីរនាក់នេះបានរស់នៅជាមួយឪពុកម្តាយខ្លួនតាំងពីតូចមក។ ខ្លួនសុខចិត្តរ៉ាប់រងបំណុលទាំងអស់ លើកលែងតែបំណុលដែលខ្ចីប្រាក់ពីធនាគារអេស៊ីលីដា ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ មានចំនួនប្រាំមួយពាន់ដុល្លារអាមេរិចទុកឲ្យចុងចម្លើយជាអ្នករ៉ាប់រងសងដោយខ្លួនឯង។ ខ្លួនសុំគ្រប់គ្រងដី និងផ្ទះសំណាក់យីហោឈានឡើង និងបន្ទប់ខារ៉ាអូខេ ដែលសង់លើដីទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ និងដីលំនៅដ្ឋានមួយកន្លែងទៀត ដែលមានទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ដែលស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ ដើម្បីទុកឲ្យកូននៅពេលកូនឈ្មោះ [redacted] ហេងហេង មានអាយុ ២១ឆ្នាំ។ ខ្លួនសុខចិត្តប្រគល់ដីលំនៅដ្ឋាន និងផ្ទះ ដែលដីនោះមានទំហំ ១០ម៉ែត្រ គុណ ៣០ម៉ែត្រ ស្ថិតនៅភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឲ្យទៅចុងចម្លើយជាអ្នកគ្រប់គ្រង ដោយទុកឲ្យកូនប្រសិនបើកូនចង់ទៅរស់ទីនោះពេលណានោះ។ ខ្លួនសុខចិត្តប្រគល់ប្រាក់ចំនួន ២២ ០០០(ពីរម៉ឺនពីរពាន់)ដុល្លារអាមេរិចឲ្យទៅចុងចម្លើយ ដោយប្រគល់ឲ្យជាពីរដំណាក់កាល គឺដំណាក់កាលទី១ ខ្លួននឹងប្រគល់ឲ្យចុងចម្លើយនូវទឹកប្រាក់ចំនួន ១១ ០០០(មួយម៉ឺនមួយពាន់)ដុល្លារអាមេរិច នៅសប្តាហ៍ទី១នៃខែមករា ឆ្នាំ២០១៣ ហើយដំណាក់កាលទី២ ខ្លួននឹងប្រគល់ឲ្យចុងចម្លើយនូវទឹកប្រាក់ចំនួន ១១ ០០០(មួយម៉ឺនមួយពាន់)ដុល្លារអាមេរិចទៀត នៅសប្តាហ៍ទី៤ នៃខែកុម្ភៈ ឆ្នាំ២០១៣។ ចំពោះទ្រព្យអ្វីទៀតខ្លួនលែងគិតហើយ។

-ចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា បានធ្វើសេចក្តីថ្លែងការណ៍ថា: ខ្លួនសុំឯកភាពលែងលះ និងសុខចិត្ត

ឲ្យដើមចោទជាអ្នកគ្រប់គ្រងកូនទាំងពីរ។ ចំពោះបំណុលនៅធនាគារអេស៊ីលីដា ខ្លួនសុខចិត្តកាប់រងសងបំណុលដែលខ្ចីធនាគារអេស៊ីលីដា តាមកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១២ ដែលខ្ចីចំនួន ៦០០០(ប្រាំមួយពាន់)ដុល្លារអាមេរិច បំណុលក្រៅពីនេះទុកឲ្យដើមចោទជាអ្នកកាប់រងសង។ ខ្លួនសុខចិត្តទទួលយកដីលំនៅឋាននិងផ្ទះ ដែលដីនោះមានទំហំ ១០ម៉ែត្រ គុណ ៣០ម៉ែត្រ ស្ថិតនៅភូមិពោធិសែនស្វាយ សង្កាត់ស្រះឫស្សី ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដោយទុកប្រគល់ឲ្យកូននៅពេលកូនចង់មករស់នៅ។ ខ្លួនឯកភាពតាមដើមចោទ ដោយទុកសុខចិត្តឲ្យដើមចោទគ្រប់គ្រងដីលំនៅឋានដែលមានទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ដែលស្ថិតនៅភូមិថ្នល់កែងឃុំរងរឿង ស្រុករវៀង ខេត្តព្រះវិហារ និងដី ព្រមទាំងផ្ទះសំណាក់យីហោឈានឡើង និងបន្ទប់ខាត់អូរខេ ដែលសង់លើដីទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរងរឿង ស្រុករវៀង ខេត្តព្រះវិហារ ដើម្បីទុកប្រគល់ឲ្យកូននៅពេលកូនស្រីឈ្មោះ[redacted] ហេងហេង មានអាយុ២១ ឆ្នាំ ហើយខ្លួនសុខចិត្តទទួលយកប្រាក់ចំនួន ២២០០០(ពីរម៉ឺនពីរពាន់)ដុល្លារអាមេរិច តាមការអះអាងរបស់ដើមចោទដែលនឹងប្រគល់ឲ្យខ្លួនតាមដំណាក់កាលដូចដែលដើមចោទបានថ្លែង។ ខ្លួនសុំយកសំភារៈប្រើប្រាស់មួយចំនួន ដូចជាគ្រែចំនួនពីរ ពូកចំនួនពីរ ទូចំនួនពីរ និងចានដែលនាងខ្ញុំទិញ ដើម្បីយកមកប្រើប្រាស់នៅផ្ទះឯពោធិសែនស្វាយ។

ដើមចោទឈ្មោះ [redacted] មនោរិទ្ធ បានថ្លែងការណ៍ថា ខ្លួនឯកភាពសុខចិត្តឲ្យសំភារៈតាមការស្នើសុំរបស់ចុងចម្លើយ។

ឈ្មោះ [redacted] ហេងហេង បានថ្លែងការណ៍ថា៖ ខ្លួនសុំរស់នៅជាមួយឪពុកឈ្មោះ[redacted]មនោរិទ្ធ។

ឈ្មោះ [redacted] វិជ្ជាត បានថ្លែងការណ៍ថា៖ ខ្លួនសុំរស់នៅជាមួយឪពុកឈ្មោះ[redacted]មនោរិទ្ធ។

មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយបានថ្លែងការណ៍ថា៖ សុំឲ្យតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

**៣. ចំនុចវិវាទ ៖ គ្មាន**

**<u>សំអាងហេតុ</u>**

ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ និងពិនិត្យភស្តុតាងរួច ឃើញថា៖

-ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាតាំងពីឆ្នាំ១៩៩៣ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅឆ្នាំ២០០៧ ។ ការរួមរស់ជាមួយគ្នាហេតុមានកូន ០២នាក់ កូនទី១ មានឈ្មោះ[redacted] ហេងហេង ភេទស្រី អាយុ ១៤ឆ្នាំ កូនទី២ មានឈ្មោះ[redacted] វិជ្ជាត ភេទប្រុស អាយុ ១២ឆ្នាំ តាមសេចក្តីថ្លែងការណ៍របស់គូភាគី។

-គូភាគីជាសហព័ទ្ធមានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដែលបានចុះសៀវភៅអាពាហ៍ពិពាហ៍នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច តាមសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍លេខ១១ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៧។

-គូភាគីបានឯកភាពលែងលះគ្នា គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-គូភាគីបានឯកភាពគ្នាប្រគល់សិទ្ធិគ្រប់គ្រងកូនកូន ០២នាក់ កូនទី១ មានឈ្មោះ[redacted] ហេងហេង ភេទស្រី អាយុ ១៤ឆ្នាំ កូនទី២ មានឈ្មោះ[redacted] វិជ្ជាត ភេទប្រុស អាយុ ១២ឆ្នាំ ឲ្យទៅដើមចោទឈ្មោះ[redacted] មនោរិទ្ធ ដោយចុងចម្លើយមិនមានបង់អាហារកិច្ចអ្វីឡើយ គប្បីតុលាការសម្រេចតាមការព្រមព្រៀងរបស់គូភាគី។

-គូភាគីបានឯកភាពគ្នាឲ្យដើមចោទជាអ្នករ៉ាប់រងសងបំណុលរួមទាំងអស់ លើកលែងតែបំណុលដែលជំពាក់ធនាគារអេស៊ីលីដាតាមកិច្ចសន្យាចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១២ ដែលខ្ទីចំនួន ៦០០០(ប្រាំមួយពាន់)ដុល្លាអាមេរិច នោះ ចុងចម្លើយជារ៉ាប់រងសង តាមការព្រមព្រៀងរបស់គូភាគី។

-គូភាគីបានឯកភាពគ្នាឲ្យដើមចោទជាអ្នកគ្រប់គ្រងលើដីលំនៅឋានដែលមានទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ដែលស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ និងដី ព្រមទាំងផ្ទះសំណាក់យីហោឈានឡើង និងបន្ទប់ខារ៉ាអូខេ ដែលសង់លើដីទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ ដើម្បីទុកប្រគល់ឲ្យកូននៅពេលកូនស្រីឈ្មោះ[redacted] ហេងហេង មានអាយុ២១ ឆ្នាំ តាមការព្រមព្រៀងរបស់គូភាគី។

-គូភាគីបានឯកភាពគ្នាឲ្យចុងចម្លើយជាអ្នកគ្រប់គ្រងដីលំនៅឋាន និងផ្ទះ ដែលដីនោះមានទំហំ ១០ ម៉ែត្រ គុណ ៣០ម៉ែត្រ ស្ថិតនៅភូមិពោធិសែនស្ទាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដើម្បីទុកប្រគល់ឲ្យកូននៅពេលកូនត្រូវការ តាមការព្រមព្រៀងរបស់គូភាគី។

-គូភាគីបានឯកភាពគ្នាឲ្យដើមចោទប្រគល់ប្រាក់ចំនួន ២២ ០០០(ពីរម៉ឺនពីរពាន់)ដុល្លាអាមេរិច ទៅចុងចម្លើយ ដោយការប្រគល់មានពីរដំណាក់កាល គឺដំណាក់កាលទី១ ដើមចោទប្រគល់ប្រាក់ចំនួន ១១ ០០០(មួយម៉ឺនមួយពាន់)ដុល្លាអាមេរិច ឲ្យទៅចុងចម្លើយនៅសប្តាហ៍ទី១ ខែមករា ឆ្នាំ២០១៣ និងដំណាក់កាលទី២ ដើមចោទប្រគល់ប្រាក់ចំនួន ១១ ០០០(មួយម៉ឺនមួយពាន់)ដុល្លាអាមេរិចទៀត ឲ្យទៅចុងចម្លើយនៅសប្តាហ៍ទី ៤ ខែកុម្ភៈ ឆ្នាំ២០១៣ តាមការព្រមព្រៀងរបស់គូភាគី។

-ប្រាក់ប្រដាប់ក្តី ដែលដើមចោទបង់ហើយនោះ គប្បីតុលាការសម្រេចរ៉ាប់អូស។

## សេចក្តីសម្រេចបញ្ចប់

១-ឲ្យដើមចោទឈ្មោះ[redacted]មនោរិទ្ធ និងចុងចម្លើយឈ្មោះ[redacted]សេរីកញ្ញា លែងលះពីគ្នាចាប់ពីពេលសាលក្រមចូលស្ថាពរតទៅ តាមបញ្ញត្តិមាត្រា ៩៧៩ នៃក្រមរដ្ឋប្បវេណី។

២-ឲ្យចុងចម្លើយឈ្មោះ [redacted]សេរីកញ្ញា ស្ថិតក្នុងភាពមេម៉ាយចំនួន ១២០ថ្ងៃ គិតចាប់ពីពេលសាលក្រមចូលស្ថាពរតទៅ តាមបញ្ញត្តិមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី។

៣-ឲ្យដើមចោទឈ្មោះ [redacted]មនោរិទ្ធ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ[redacted] ហេងហេង ភេទស្រី អាយុ ១៤ឆ្នាំ និងឈ្មោះ[redacted]វិជ្ជាត ភេទប្រុស អាយុ ១២ឆ្នាំ តាមការព្រមព្រៀងរបស់គូភាគី តាមបញ្ញត្តិមាត្រា ១០៣៧ នៃក្រមរដ្ឋប្បវេណី។

៤-ឲ្យចុងចម្លើយឈ្មោះ[redacted]សេរីកញ្ញា ជាម្តាយ ដែលពុំមានអំណាចមេបាលើកូនឈ្មោះ [redacted] ហេងហេង ភេទស្រី អាយុ ១៤ឆ្នាំ និងឈ្មោះ[redacted]វិជ្ជាត ភេទប្រុស អាយុ ១២ឆ្នាំ មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយ ដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន តាមបញ្ញត្តិមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី។

៥-ឲ្យដើមចោទឈ្មោះ[redacted] មនោរិទ្ធ ជាអ្នកមានសិទ្ធិគ្រប់គ្រងលើដីលំនៅឋានដែលមានទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ដែលស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ និងដី ព្រមទាំងផ្ទះសំណាក់យីហោឈានឡើង និងបន្ទប់ខារ៉ាអូខេ ដែលសង់លើដីទំហំ ២១ម៉ែត្រ គុណ ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំ



Scanned with CamScanner

១១/១

ងរៀង ស្រុករៀង ខេត្តព្រះវិហារ ដើម្បីទុកប្រគល់ឲ្យកូននៅពេលកូនទាំងពីរនាក់មានវ័យជានីតិជន តាមការព្រមព្រៀងរបស់គូភាគី។

៦-ឲ្យចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា ជាអ្នកមានសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋាន និងផ្ទះ ដែលដីនោះមានទំហំ ១០ម៉ែត្រ គុណ ៣០ម៉ែត្រ ស្ថិតនៅភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដើម្បីទុកប្រគល់ឲ្យកូននៅពេលកូនទាំងពីរនាក់មានវ័យជានីតិជន តាមការព្រមព្រៀងរបស់គូភាគី។

៧-ឲ្យដើមចោទឈ្មោះ [redacted] មនោរិទ្ធ ជាអ្នកប៉ះប៉ូវសងបំណុលរួមទាំងអស់ លើកលែងតែបំណុលដែលជំពាក់ធនាគារអេស៊ីលីដាតាមកិច្ចសន្យាចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០១២ ដែលខ្ចីចំនួន ៦០០០(ប្រាំមួយពាន់) ដុល្លាអាមេរិច នោះ ចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា ជាប៉ះប៉ូវសង តាមការព្រមព្រៀងរបស់គូភាគី។

៨-ឲ្យដើមចោទឈ្មោះ [redacted] មនោរិទ្ធ ប្រគល់ប្រាក់ចំនួន ២២ ០០០(ពីរម៉ឺនពីរពាន់)ដុល្លាអាមេរិច ទៅចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា ដោយការប្រគល់មានពីរដំណាក់កាល គឺដំណាក់កាលទី១ ដើមចោទប្រគល់ប្រាក់ចំនួន ១១ ០០០(មួយម៉ឺនមួយពាន់)ដុល្លាអាមេរិច ឲ្យទៅចុងចម្លើយនៅសប្តាហ៍ទី១ ខែមករា ឆ្នាំ២០១៣ និងដំណាក់កាលទី២ ដើមចោទប្រគល់ប្រាក់ចំនួន ១១ ០០០(មួយម៉ឺនមួយពាន់)ដុល្លាអាមេរិចទៀត ឲ្យទៅចុងចម្លើយនៅសប្តាហ៍ទី៤ ខែកុម្ភៈ ឆ្នាំ២០១៣ តាមការព្រមព្រៀងរបស់គូភាគី។

៩-រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់រួចហើយ។

សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ ហើយសាម៉ីខ្លួនមានសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

[redacted]